ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២១

នៅក្នុងខែមីនា ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន១លើក

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ

-បានអនុញ្ញាតឱ្យលោកជំទាវបណ្ឌិត **ផាន ទ្បេ ឈិង** ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋសិង្ហបុរី ចូលជួបសវនាការ និងសម្តែងការគួរសម។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមថ្វាយដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ស្តេចយាងពិនិត្យព្រះរាជសុខភាព នៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន

-បានអញ្ជើញផ្តល់ភ្លើងបូជាសពឧបាសិកា **កែវ ហ៊ាង** ម្តាយបង្កើតរបស់ឯកឧត្តម **គឹម ផា** លេខាធិការគណៈកម្មការទី៦ ព្រឹទ្ធសភា ស្ថិតភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

-បានអញ្ជើញចូលរួមពិធីបុណ្យសពលោកឧត្តមសេនីយ៍ទោ **ខាត់ សារ៉ាត់** នៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន១ច្បាប់

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៦៣ច្បាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន៦១ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៦១ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៥៦ច្បាប់

-បានទទួលសំណើពីរដ្ឋសភា និងសំណើប្រមុខរដ្ឋស្តីទីចំនួន២ច្បាប់

-បានទទួលសំណើពីក្រុមប្រឹក្សាធម្មនុញ្ញចំនួន១ច្បាប់

-បានទទួលសំណើពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន១ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន១លើក។

ក.សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន ២លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន១លើក។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះពិនិត្យការកសាងសមិទ្ធផលនានា និងនាំយកព្រះរូបសំណាក សម្តេចព្រះសង្ឃរាជ **ជួន ណាត** មកតម្កល់ទុកនៅវត្តទេពនិម្មិត ហៅវត្តអញ្ចាញ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៣ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

ក.សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន១លើក ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម កា** ប្រធានស្តីទីព្រឹទ្ធសភា។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ នាំយកមីចំនួន ២.០០០កេស និងទឹកសុទ្ធចំនួន២.០០០កេស ជូនរដ្ឋបាលសាលាខេត្តកណ្តាលសម្រាប់

ចែកជូនបងប្អូនប្រជាពលរដ្ឋ ដែលកំពុងធ្វើចត្តាឡីស័ក តាមបណ្តាស្រុក ក្រុង ទូទាំងខេត្ត កណ្តាល។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៧ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំចំនួន២លើក ដើម្បីពិនិត្យ និងសម្រេច លើសំណើរបស់រដ្ឋសភា និងសំណើរបស់គណៈកម្មការទី៨ព្រឹទ្ធសភា សុំដាក់សេចក្តី ព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ទៅក្នុងរបៀបវារៈប្រជុំព្រឹទ្ធសភាជា វិសាមញ្ញ។

## ៣.សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ចំនួន១លើក ដើម្បីពិនិត្យ និង ឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីប្រមូលព័ត៌មាន ផ្សព្វផ្សាយច្បាប់ និងតាម ដានអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោត លើបញ្ហាលើកកម្ពស់សមភាពយេនឌ័រ និងសុខភាពសាធារណៈ ការរស់នៅ និងការធ្វើ ការងារតាមគន្លងថ្មីស្របតាមបរិបទកូវីដ-១៩ នៅខេត្តរតនគិរី។

### ៤.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៨ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័ន ពាក់ព័ន្ធបានចំនួន១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៨ករណី និងឆ្លើយតបទៅ

ម្ចាស់បណ្តឹងបានចំនួន៨ករណី និងកំពុងពិនិត្យសិក្សាបានចំនួន៥ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន១ករណី

-អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី និងលោកជំទាវ ចែកជូនប្រជាពលរដ្ឋកំពុងធ្វើចត្តាឡីស័ក នៅរាជធានីភ្នំពេញចំនួន៦៨៩នាក់

-បានអញ្ជើញចូលរួមប្រជុំជាមួយក្រុមប្រឹក្សាស្រុក ឃុំ សង្កាត់ ភូមិ និងមេប៉ុស្តិ៍ ដើម្បីពិភាក្សា និងពិគ្រោះយោបល់អំពីការលំបាក និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងបានផ្តល់នូវអនុសាសន៍មួយចំនួនក្នុងការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋដោយតម្លាភាព និងគុណភាព ពិសេសត្រូវអនុវត្តវិធានការពារការពារ និង៣កុំ នៅខេត្តឧត្តរមានជ័យ

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាខេត្ត ប្រឹក្សាស្រុក អភិបាលនៃគណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ នាយ-ប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងផ្តល់ការណែនាំអំពីការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងលើកទឹកចិត្តឱ្យឃុំរៀបចំបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន និងគ្រប់ភូមិឱ្យបង្កើតក្រុមដោះស្រាយទំនាស់តាមសំណូមពរនានាក្នុងមូលដ្ឋាន នៅស្រុកគីរីសាគរ ស្រុកកោះកុង ខេត្តកោះកុង

-បានអញ្ជើញផ្តល់កិច្ចសម្ភាសក្នុងនាមជាសមាជិកព្រឹទ្ធសភាដែលជាស្ត្រី ជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍកម្ពុជា ក្រោមប្រធានបទស្តីពីការឈ្វេងយល់ពីឧបសគ្គ និងមាគ៌ាឆ្ពោះទៅរកការចូលរួមក្នុងវិស័យនយោបាយរបស់ស្ត្រីតាមប្រព័ន្ធវីដេអូ

-បានអញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតអង្គភាពកិច្ចការសុខភាព និងសង្គមកិច្ច នៃព្រឹទ្ធសភា និងការកំណត់តួនាទី ភារកិច្ច រចនាសម្ព័ន្ធនៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា

-សមាជិកព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខក្រុម

ប្រឹក្សាឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់គោលដៅ ដើម្បីឈ្វេងយល់អំពីស្ថានភាពរស់នៅ និងការប្រកបរបររបស់បងប្អូនប្រជាពលរដ្ឋ ក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ផ្សព្វផ្សាយណែនាំការប្រើប្រព័ន្ធ QR code ព្រមទាំងបានផ្ដាំផ្ញើដល់អាជ្ញាធរមូលដ្ឋាន ត្រូវបន្តគោរពឱ្យបានម៉ឺងម៉ាត់តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងអនុវត្តវិធានការ៣ការពារ និង៣កុំ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងឈានទៅការបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ នាពេលខាងមុខ នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ។

-សមាជិកព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងចូលរួមពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានាចំនួន៨០លើក។

## ៤.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ា (AIPA) បានអញ្ជើញចូលរួមប្រជុំរវាងសភាសមាជិកអាយប៉ា និងសភានៃព្រះរាជាណាចក្រណ័រវេ (Meeting between AIPA-Norwegian Parliament ) តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីទីក្រុងហ្សាកាតា។

ថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

កិត្តិសង្គហបណ្ឌិត **ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូរលេខា និងផ្ទុនតាមបណ្ដាញព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*